# មេរៀនទី ១៤៩៖ ស្តេចយ៉ូសៀសសន្យាថាដើរតាមព្រះជាម្ចាស់

## ២ របាក្សត្រ ៣៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/uf2iFYRaUEg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/_zTirEPOxV4

**គោលបំណង៖** ព្រះមានបន្ទូលមកកាន់យើងតាមរយៈព្រះគម្ពីរ។

**ខគម្ពីរចងចាំ៖** ទំនុកដំកើង ១១៩៖១០៥ *"ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំផង។"*

**ចំរៀង** ( *យូធូបលីង* )៖

១. មួយ ពីរ ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/32BRXvDba4w

២. មានភ្នែកសម្រាប់មើលគម្ពីរ https://youtu.be/tkkzkjEjDnA

៣. ក្នុងពេលទ្រង់ https://youtu.be/uOmu3Qm5pr0

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត « **ឆ្លងកាត់ឧបសគ្គ** »



សំភារៈដែលត្រូវការ៖ កៅអី តុ ក្រមា ធុងទឹក ដុំថ្ម( តាមស្ថានភាពទីតាំង )

១. យើងបែងចែកកុមារជា២ក្រុម

២. ក្រុមនីមួយៗត្រូវរើសកុមារម្នាក់មកដើម្បី រុំភ្នែករបស់គេជាមួយនឹងក្រមា



៣. យើងត្រូវ យកសំភារៈ មកដាក់ពង្រាយក្នុងថ្នាក់រៀនធ្វើជាឧបសគ្គ

៤. ឲ្យកុមារដែលត្រូវគេចង់ភ្នែកនោះ ដើរកាត់ឧបសគ្គនៅក្នុងថ្នាក់រៀន ហើយឲ្យកុមារនោះដើរត្រឡប់ទៅកន្លែងដើមវិញដោយមិនឲ្យដើរជាន់ឧបសគ្គទាំងអស់នោះ។ ក្រុមដែលបានដើរកាត់ឧបសគ្គទាំងអស់បានមុនគេគឺ ជាអ្នកឈ្នះល្បែងនេះ។

៥. សូមពន្យល់ប្រាប់កុមារថា វាពិបាកខ្លាំងណាស់ក្នុងការដើរឆ្លងកាត់ឧបសគ្គទាំងអស់ដែលយើងមិនអាចមើលឃើញ ឬគ្មាននរណាម្នាក់ជួយយើង។ ហើយក៏ដូចគ្នានឹងជីវិតយើងចឹងដែរ វានឹងពិបាករស់នៅណាស់បើគ្មានការដឹកនាំពីព្រះ។

### ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់សាកល្បងអ្វីដែលថ្មីដោយគ្មានការជួយពីអ្នកដទៃដែរឬទេ? តើអ្នកអាចរៀនជិះកង់ដោយគ្មានអ្នកណាជួយដែរឬទេ? តើអ្នកអាចរៀនហែលទឹកម្នាក់ឯងដោយគ្មានអ្នកណាជួយដែលឬទេ? នៅក្នុងជីវិតវាមានអ្វីជាច្រើនដែលយើងមិនអាចធ្វើដោយគ្មានការជួយពីអ្នកដទៃ។ ប៉ុន្តែការជួយដ៏ពិតប្រាកដគឺយើងត្រូវការ ការជួយពីព្រះ។ ថ្ងៃនេះយើងនឹងរៀនអំពីរបៀបដែលព្រះបានជួយដឹកនាំផ្លូវយើងជារៀងរាល់ថ្ងៃ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងសាច់រឿងព្រះគម្ពីរ ប្រជារាស្ត្ររបស់ព្រះបានភ្លេចអស់ក្នុងការថ្វាយបង្គំព្រះដ៏ពិតតែ១។ ពួកគេបានថ្វាយបង្គំរូបព្រះដែលពួកគេបានបង្កើតឡើងចេញពីឈើ ថ្ម និងលង្ហិន។ បន្ទាប់មកស្តេចថ្មីក៏បានកាន់កាប់អំណាចហើយគាត់ទើបតែមានអាយុ៨ឆ្នាំ! ស្តេចនោះឈ្មោះថា យ៉ូសៀស ហើយគាត់ស្រឡាញ់ព្រះ។ យ៉ូសៃលបានឲ្យមនុស្សជាច្រើនទៅបំផ្លាញរូបព្រះទាំងអស់ដែលពួកគេបានបង្កើត។ ស្តេចបានឲ្យមនុស្សជួសជុល និងសំអាតព្រះវិហាររបស់ព្រះដែលពីមុនបានដាក់សុទ្ធតែរូបព្រះពេញព្រះវិហារ។

បន្ទាប់មកក្រុមការងាររបស់ស្តេចយ៉ូសៀលបានប្រទះឃើញព្រះគម្ពីរនៅក្នុងព្រះវិហារ។ គ្មាននរណាម្នាក់បានអានព្រះគម្ពីរជាយូរឆ្នាំមកហើយ។ គ្មាននរណាអាចចងចាំថានៅក្នុងព្រះគម្ពីរនិយាយពីអ្វីទេ។ យ៉ូសៀល រំភើបចិត្តដើម្បីរៀនអំពីព្រះនៅក្នុងព្រះគម្ពីរ។ ទ្រង់បានប្រមូលមនុស្សគ្រប់គ្នាមកជុំគ្នានៅក្នុងស្រុកយូដា ហើយទ្រង់បានអានព្រះគម្ពីរឲ្យមនុស្សគ្រប់គ្នាស្តាប់។

ទ្រង់គឺជាស្តេច ដូច្នេះទ្រង់អាចបញ្ជារឲ្យនរណាម្នាក់ផ្សេងទៀតអានព្រះគម្ពីរក៏បាន ប៉ុន្តែយ៉ូសៀលចង់អានព្រះគម្ពីរដោយខ្លួនឯងឲ្យប្រជារាស្ត្ររបស់ទ្រង់ស្តាប់។ នៅពេលដែលយ៉ូសៀលអានអ្វីដែលមានក្នុងព្រះគម្ពីររួច ទ្រង់បានសន្យាថានឹងដើរតាមព្រះជានិច្ច ហើយប្រជារាស្ត្ររបស់ព្រះអង្គក៏ធ្វើដូចទ្រង់។ ទោះបីគាត់ជាស្តេចក៏ដោយ តែយ៉ូសៀលដឹងថាគាត់មិនអាចរស់នៅដោយគ្មានការដឹកនាំពីព្រះដែលគាត់បានរកឃើញនៅក្នុងព្រះគម្ពីរនោះទេ។

នៅពេលដែលមនុស្សឈប់អានព្រះគម្ពីរ ពួកគេចាប់ផ្តើមថ្វាយបង្គំរូបព្រះ។ ពួកគេមិនមានការដឹកនាំល្អសំរាប់ជីវិតគេនោះទេ មានមនុស្សជាច្រើនបានធ្វើការជ្រើសរើសខុស។ យ៉ូសៀលគាត់ជាស្តេចដ៏ក្មេងបំផុត គាត់ទើបតែមានអាយុ៨ឆ្នាំ ប៉ុន្តែគាត់ស្រឡាញ់ព្រះ ហើយគាត់ចង់ជ្រើសជំរើសដែលនឹងធ្វើឲ្យព្រះសប្បាយព្រះទ័យ។

តើអ្នកចង់ឲ្យព្រះដឹកនាំអ្នក និងជួយអ្នកដើម្បីជ្រើសរើសជំរើសល្អសំរាប់ជីវិតអ្នកដែរឬទេ? ដូច្នេះអ្នកគួរតែសិក្សាព្រះគម្ពីរដូចជាយ៉ូសៀល។ ព្រះគម្ពីរគឺដូចជាផែនទីដែលជួយយើងធ្វើដំណើរឆ្ពោះទៅទិសដៅដែលព្រះចង់ឲ្យយើងទៅ! ព្រះមានបន្ទូលមកកាន់យើងតាមរយៈព្រះគម្ពីរ!

## ៦. សំនួរពិភាក្សា

១. តើស្តេចពីស្រុកយូដាដែលបំផ្លាញរូបព្រះទាំងអស់នោះឈ្មោះអ្វី? *(យ៉ូសៀស)*

២. តើព្រះអង្គមានអាយុប៉ុន្មានពេលឡើងសោយរាជ្យ? *(អាយុ ៨ ឆ្នាំ)*

៣. តើព្រះអង្គបានរកឃើញអ្វីខ្លះ ពេលកំពុងជួសជុល និងសម្អាតព្រះវិហារ? *(ព្រះគម្ពីរ)*

៤. ហេតុអ្វីគាត់រំភើបចិត្តពេលបានរកឃើញព្រះគម្ពីរ? *(គាត់បានដឹងថាវាជាព្រះបន្ទូលរបស់ព្រះ)*

៥. ហេតុអ្វីយើងគួរអានព្រះគម្ពីរ? *(ព្រះមានបន្ទូលមកយើងតាមរយៈព្រះគម្ពីរ វាដូចជាផែនទីដែលបង្ហាញយើងពីទិសដៅដែលព្រះចង់ឲ្យយើងទៅ)*

## ៧. ល្បែងកំសាន្ត « ឆ្លងកាត់ឧបសគ្គ »

សំភារៈត្រូវការមានដូចជា កៅអី តុ ក្រមា ធុងទឹក ដុំថ្ម(តាមស្ថានភាពទីតាំង)

១. យើងបែងចែកកុមារជា២ក្រុម

២. ក្រុមនីមួយៗត្រូវរើសកុមារម្នាក់មកដើម្បី រុំភ្នែករបស់គេជាមួយនឹងក្រមា

៣. យើងត្រូវ យកសំភារៈ មកដាក់ពង្រាយក្នុងថ្នាក់រៀនធ្វើជាឧបសគ្គ

៤. ឲ្យកុមារដែលត្រូវគេចង់ភ្នែកនោះ ដើរកាត់ឧបសគ្គនៅក្នុងថ្នាក់រៀន



ហើយឲ្យកុមារនោះដើរត្រឡប់ទៅកន្លែងដើមវិញដោយមិនឲ្យដើរជាន់ឧបសគ្គ ទាំងអស់នោះ។ ក្រុមដែលបានដើរកាត់ឧបសគ្គទាំ ងអស់បានមុនគេគឺជា អ្នកឈ្នះល្បែងនេះ។ **<u>ប៉ុន្តែលើកនេះ ពួកគេនិងមានដៃគូរក្នុងការជួយប្រាប់ពួកគេ។</u>** ក្រុមណាដែលអាច ឆ្លងកាត់ឧបសគ្គនេះបានបានលឿនជាងគេក្រុមនោះជាអ្នកឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់ប្រាប់កុមារថា វាគឺមានភាពងាយស្រួលក្នុងការលេងល្បែងនេះជាងមុន នៅពេលដែលយើងមានដៃគូរក្នុងការជួយយើង។ ព្រះគឺតែងតែជួយដល់យើងតាមរយៈព្រះគម្ពីរ។ សូមឲ្យយើងបាន ប្តេជ្ញាចិត្តក្នុងការអាន និងរៀនព្រះគម្ពីរ ជារៀងរាល់ថ្ងៃ។

**៨. ខគម្ពីរចងចាំ**

**ទំនុកដំកើង ១១៩៖១០៥** *"ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំហើយជា ពន្លឺបំភ្លឺផ្លូវទូលបង្គំផង។"*

**៩. ហត្ថកម្ម "ព្រះបន្ទូលរបស់ព្រះដឹកនាំផ្លូវយើង"**

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម កូល័រផាត់ព៌ណ កន្ត្រៃ និងការ



១. សរសេរខគម្ពីរចងចាំនៅលើជើងទ្រទៀន

២. ផាត់ព៌ណ និងតុបតែងទៀន

៣. កាត់រូបទាំងអស់ចេញមក ហើយយកការបិត ហើយតុបតែងវាឲ្យចេញជាទៀនបង្សួរ

៤. ហើយអានខគម្ពីរចងចាំជាមួយគ្នា

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើយើងនឹងនៅឯណាបើយើងគ្មានព្រះយេស៊ូវគង់ជាមួយ? ទ្រង់ជាព្រះបន្ទូលដែលបានបង្កើតជាសាច់ឈាម ហើយទ្រង់ជួយយើងឲ្យរស់នៅដោយគោរពច្បាប់របស់ព្រះ។ ការអានព្រះគម្ពីរ និងការអធិស្ឋានគឺជាចំណុចសំខាន់សម្រាប់ការលូតលាស់ និងការអភិវឌ្ឍន៍របស់យើងជាគ្រិស្តបរិស័ទ។ ពិចារណាលើចំណុចនេះ៖ តើការថ្វាយបង្គំសំរាប់ជីវិតផ្ទាល់ខ្លួនរបស់អ្នកយ៉ាងណាដែរ? តើមានអ្វីដែលជាការល្អអំពីការថ្វាយបង្គំនេះ? ហើយអ្វីដែលត្រូវផ្លាស់ប្តូរ? ព្រះទ្រង់មានព្រះហឫទ័យចង់បង្ហាញដល់អ្នកជាច្រើន។ មិនថាអ្នកនឹងទៅណានៅថ្ងៃនេះទេ សូមប្រាកដថាត្រូវចំណាយពេលខ្លះដើម្បីបើកព្រះគម្ពីរអានព្រះបន្ទូលរបស់ព្រះ ហើយស្តាប់សំឡេងរបស់ព្រះ។

“ព្រះបន្ទូលរបស់ព្រះដឹកនាំផ្លូវយើង”




“ព្រះបន្ទូលរបស់ព្រះដឹកនាំផ្លូវយើង”

